
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 3.08 ព្រះអម្ចាស់ជ្រើសរើសលោកគេឌាន

ជនជាតិអ៊ីស្រាអែលគឺជាប្រជារាស្ត្រដែលព្រះបានជ្រើសរើស។ ទ្រង់បានថែរក្សាពួកគេហើយឱ្យលោកម៉ូសេដឹកនាំពួកគេទៅកាន់ស្រុកកាណានដែលជាទឹកដីសន្យា។ ព្រះបានធ្វើការអស្ចារ្យ ដូច្នេះពួកគេអាចទទួលបានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ មានសុវត្ថិភាព និងសុខភាពល្អនៅពេលដែលពួកគេបន្តដំណើរ។ ប៉ុន្តែប្រជាជនមិនបានស្តាប់បង្គាប់ព្រះជានិច្ចទេ។ នៅពេលដែលពួកគេទៅដល់ស្រុកកាណានពេលខ្លះពួកគេនឹងគោរពតាមព្រះ តែពេលខ្លះពួកគេមិនបានស្តាប់បង្គាប់ទ្រង់ទេ។ ជារឿយៗវាអាស្រ័យលើអ្នកដឹកនាំរបស់ពួកគេ។ ឆ្នាំខ្លះពួកគេមានមេដឹកនាំល្អ។ ឆ្នាំខ្លះវិញពួកគេមានមេដឹកនាំដែលអាក្រក់។ ជាច្រើនដងជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបនៅចំពោះព្រះភ័ក្ត្រព្រះ។

នៅពេលមួយ ដែលជនជាតិអ៊ីស្រាអែលប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ព្រះបានអនុញ្ញាតិឱ្យជនជាតិម៉ាឌានគ្រប់គ្រងលើពួកគេ។ ជនជាតិម៉ាឌានត្រូវបានអនុញ្ញាតិឱ្យគ្រប់គ្រងលើពួកគេអស់រយៈពេលប្រាំពីរឆ្នាំ។ ពួកគេជាមនុស្សឃោរឃៅ។ នៅពេលដែលជនជាតិអ៊ីស្រាអែលដាំដំណាំពួកម៉ាឌានជីកកកាយដំណាំពួកគេ។ ពួកម៉ាឌានបានយកសត្វទាំងអស់របស់ពួកគេ ហើយក៏រឹបអូសយកអាហារផងដែរ វាធ្វើឱ្យប្រជាជនអ៊ីស្រាអែលចាប់ផ្តើមមានការស្រេកឃ្លានជាខ្លាំង។

ពេលនោះជនជាតិអ៊ីស្រាអែលក៏ចាប់ផ្តើមស្រែករកព្រះឲ្យជួយ។ ព្រះអម្ចាស់បានចាត់ព្យាការីមួយរូបឱ្យទៅរកជនជាតិអ៊ីស្រាអែល ហើយបានថ្លែងព្រះបន្ទូលព្រះទៅពួកគេថា៖ «យើងជាព្រះអម្ចាស់ជាព្រះរបស់អ្នក។ យើងបាននាំអ្នករាល់គ្នាចេញពីស្រុកអេស៊ីប។ យើងបានប្រាប់អ្នកកុំឲ្យថ្វាយបង្គំព្រះក្លែងក្លាយ។ អ្នកមិនបានស្តាប់បង្គាប់យើងទេ» ប៉ុន្តែពេលនោះព្រះបានស្តាប់នៅសំរែករបស់ពួកគេ។ មានបុរសជនជាតិអ៊ីស្រាអែលម្នាក់ដែលរស់នៅទីនោះឈ្មោះថា គេឌាន។ មានទេវតាមួយរូបមកប្រាប់គាត់ថា៖ «ព្រះអម្ចាស់គង់នៅជាមួយអ្នក! » ហើយព្រះអម្ចាស់មានព្រះបន្ទូលទៅគេឌានថាៈ «ចូរចេញទៅដោយប្រើកម្លាំងដែលអ្នកមានហើយសង្គ្រោះប្រជារាស្ត្រអ៊ីស្រាអែលពីជនជាតិម៉ាឌាន»។

លោកគេឌានមានការសង្ស័យក្នុងការជឿថាព្រះទ្រង់កំពុងតែប្រើគាត់ឬយ៉ាងណា។ គាត់បាននិយាយថា "គ្រួសាររបស់ខ្ញុំជាគ្រួសារខ្សោយជាងគេបំផុតនៅទីនេះ ហើយខ្ញុំជាមនុស្សដែលមិនសំខាន់សោះនៅក្នុងគ្រួសាររបស់ខ្ញុំទាំងមូល!"ព្រះមានបន្ទូលថា" កុំបារម្ភអី! យើងនឹងគង់នៅជាមួយអ្នក ហើយអ្នកនឹងអាចបំផ្លាញពួកម៉ាឌានបាន។ លោកគេឌានបានសុំឲ្យព្រះបង្ហាញទីសំគាល់ណាមួយ ដែលបញ្ជាក់ថា ព្រះពិតជាកំពុងតែមានព្រះបន្ទូលមកគាត់មែន។ គាត់ចង់បានភស្តុតាងមួយ។ គាត់សួរទៅកាន់ព្រះអម្ចាស់ថា៖ «ប្រសិនបើព្រះអង្គពិតជាចង់ឱ្យទូលបង្គំជួយសង្គ្រោះជនជាតិអ៊ីស្រាអែលឱ្យរួចផុតពីជនជាតិម៉ាឌានមែន សូមបង្ហាញឱ្យទូលបង្គំឃើញតាមវិធីនេះ យប់នេះទូលបង្គំនឹងដាក់ស្បែកចៀមនៅលើដី (ស្បែកចៀមដែលបានពីចៀម)។ ព្រឹកឡើងពេលខ្ញុំភ្ញាក់ពីដំណេក ប្រសិនបើស្បែកចៀមសើមពីទឹកសន្សើមនៅពេលព្រឹក តែដីនៅតែស្ងួតនៅឡើយខ្ញុំដឹងថាពិតជាទ្រង់ដែលមានព្រះបន្ទូលមកខ្ញុំ ហើយខ្ញុំនឹងអាចចេញទៅសង្គ្រោះអ៊ីស្រាអែលបាន។ព្រឹកឡើងពេលដែលលោកគេឌានក្រោកពីដំណេកគាត់បានឃើញថាស្បែកចៀមសើមជាមួយទឹកសន្សើមពេលព្រឹកតែដីនៅតែស្ងួតដូចជាអ្វីដែលគាត់បានទូលសុំ។

ប៉ុន្តែលោកគេឌានចង់ឱ្យព្រះបង្ហាញអង្គទ្រង់ម្តងទៀត។ លោកគេឌានបានទូលព្រះថាកុំក្រោធនឹងទូលបង្គំឡើយ។ ប៉ុន្តែតើទ្រង់អាចបញ្ជាក់បានទេថា ពិតជាព្រះមែនដែលបានចាត់ខ្ញុំឱ្យចេញទៅរំដោះជនជាតិអ៊ីស្រាអែល? ខ្ញុំនឹងដាក់ស្បែកចៀមម្តងទៀតនៅយប់នេះ។ នៅពេលព្រឹកប្រសិនបើស្បែកចៀមស្ងួតហួតហែងតែដីសើមខ្ញុំនឹងដឹងថាគឺ ព្រះអង្គជាព្រះជាអម្ចាស់ដែលបានចាត់ខ្ញុំឱ្យចេញទៅសង្គ្រោះអ៊ីស្រាអែល។ នៅពេលព្រឹកឡើងស្បែកចៀមស្ងួតទាំងស្រុង ប៉ុន្តែដីនៅជុំវិញគឺសើម។ លោកគេឌានទទួលបានទីសំគាល់ពីព្រះជាអម្ចាស់។ គាត់ដឹងថាព្រះទ្រង់ប្រើគាត់ដើម្បីជួយសង្គ្រោះប្រជារាស្ត្រអ៊ីស្រាអែលមែន ។ យើងនឹងឃើញថាតើរឿងនោះកើតឡើងយ៉ាងដូចម្តេចទៀតនៅក្នុងមេរៀនបន្ទាប់!

**ចៅហ្វាយ ៦**

## 3.08 **ព្រះអម្ចាស់ជ្រើសរើស លោកគេឌាន - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន**

**១)** ប្រជាជនរបស់ព្រះគឺជនជាតិអ៊ីស្រាអែលមិនបានស្តាប់បង្គាប់ព្រះទេ។ ព្រះបានអនុញ្ញាតឲ្យជនជាតិម៉ាឌានដ៏ឃោរឃៅគ្រប់គ្រងលើពួកគេ។ ពួកម៉ាឌានបានរឹបអូសយកអាហាររបស់ពួកគេ ហើយវាធ្វើឱ្យពួកគេចាប់ផ្តើមស្រេកឃ្លានជាខ្លាំង។ ប្រជាជនអ៊ីស្រាអែលបានស្រែករកព្រះឲ្យជួយ។

**២)** ព្រះបានជ្រើសរើសលោកគេឌានឲ្យទៅសង្គ្រោះជនជាតិអ៊ីស្រាអែលពីពួកម៉ាឌាន។ លោកគេឌានមិនជឿថាគាត់មានកម្លាំងគ្រប់គ្រាន់ ឬថាគាត់មិនសំខាន់គ្រប់គ្រាន់ក្នុងការបំពេញការងារនេះទេ ។ ព្រះអម្ចាស់ទ្រង់មានបន្ទូលថា "ខ្ញុំនឹងគង់នៅជាមួយអ្នក" ។

**៣)** លោកគេឌានបានសុំព្រះនៅទីសំគាល់មួយ។ លោកគេឌានដាក់ស្បែកចៀមនៅលើដីនៅយប់នោះហើយបានសុំព្រះធ្វើឱ្យវាសើមដោយសំណើមពេលព្រឹក ប៉ុន្តែឱ្យដីនៅតែស្ងួត។ ព្រះបានធ្វើដូចដែលលោកគេឌានបានទូលសូម ។

**៤)** លោកគេឌានបានសុំទីសំគាល់ទីពីរ។ លោកគេឌានដាក់ស្បែកចៀមនៅលើដីជាលើកទីពីរ។ គាត់បានស្នើសុំឱ្យព្រះធ្វើឱ្យស្បែកចៀមស្ងួតនៅព្រឹកបន្ទាប់ប៉ុន្តែឱ្យដីនៅតែសើម។ ជាថ្មីម្តងទៀតព្រះបានឆ្លើយតប ដូចដែលគេឌានបានទូលសូម ។

**៥)** លោកគេឌានដឹងថា ព្រះទ្រង់បានជ្រើសរើសគាត់ឲ្យសង្គ្រោះជនជាតិអ៊ីស្រាអែល ។

### សំណួរ

១) តើមានអ្វីកើតឡើងនៅពេលដែលជនជាតិអ៊ីស្រាអែលមិនស្តាប់បង្គាប់ព្រះអម្ចាស់ ?

២) តើព្រះបានជ្រើសរើសអ្នកណាដើម្បីជួយសង្គ្រោះជនជាតិអ៊ីស្រាអែលពីពួកម៉ាឌាន ?

៣) ពេលលោកគេឌានមិនជឿថាព្រះអាចប្រើគាត់ តើព្រះមានបន្ទូលថាដូចម្តេច ?

៤) តើលោកគេឌានបានសុំទីសំគាល់អ្វីពីព្រះ ?

៥) តើអ្វីជាទីសំគាល់ទីពីរដែលលោកគេឌានបានស្នើសុំពីព្រះ ?

### ចម្លើយ

១) ព្រះបានអនុញ្ញាតឲ្យពួកម៉ាឌានដ៏ឃោរឃៅគ្រប់គ្រងពួកគេអស់រយៈពេល ៧ ឆ្នាំ។

២) ព្រះបានជ្រើសរើសលោកគេឌានឲ្យជួយសង្គ្រោះជនជាតិអ៊ីស្រាអែល។

៣) ព្រះបានប្រាប់លោកគេឌានថា យើងនឹងគង់នៅជាមួយអ្នក។

៤) លោកគេឌានដាក់ស្បែកចៀមនៅខាងក្រៅ។ គាត់បានស្នើសុំឱ្យព្រះធ្វើឱ្យស្បែកចៀមសើម ហើយដីនៅតែ ស្ងួត ។

5) លោកគេឌានដាក់ស្បែកចៀមម្តងទៀត ។ នៅពេលនេះគាត់បានស្នើសុំព្រះឱ្យធ្វើឱ្យស្បែកចៀមស្ងួតហើយឱ្យដីនៅតែសើមដដែល ។



Kids of Destiny®
Reaching the Next Generation

www.kidsofdestiny.org